THE SCHOOL DISTRICT OF PHILADELPHIA

**អង្គភាពប្រតិបត្តិការ**
440 North Broad Street
Philadelphia, PA 19130

2 កុម្ភៈ 2021

ជូនចំពោះក្រុមគ្រួសាររបស់មណ្ឌលសិក្សាធិការ School District of Philadelphia ជាទីរាប់អាន

មណ្ឌល និងក្រុមថែទាំរបស់យើងបន្តដំឡើងកង្ហារជាប់បង្អួច និងធ្វើការជួសជុលដែលចាំបាច់ផ្សេងៗ សម្រាប់ប្រព័ន្ធបន្សុទ្ធខ្យល់ដើម្បីទ្រទ្រង់ដល់ការបន្សុទ្ធខ្យល់ឲ្យបានត្រឹមត្រូវនៅក្នុងសាលារៀនរបស់យើង ខណៈពេលដែលយើងរៀបចំដើម្បីស្វាគមន៍បុគ្គលិក និងសិស្សត្រឡប់មកវិញប្រកបដោយសុវត្ថិភាពក្នុងដំណាក់កាលសម្រាប់ការត្រឡប់ទៅបង្រៀន និងចូលរៀននៅសាលារៀនវិញ។ ជាការក្រើនរំលឹក កង្ហារជាប់បង្អួចនឹងត្រូវបានដំឡើងតែនៅក្នុងបន្ទប់ណាដែលមិនមានប្រព័ន្ធបន្សុទ្ធខ្យល់ ប៉ុន្តែមានបង្អួចដែលផ្តល់នូវខ្យល់បរិសុទ្ធចេញចូលប៉ុណ្ណោះ។

ទាំងនេះជាព័ត៌មានបីបន្ថែមទៀតដែលអ្នកគួរដឹង៖

- **ព័ត៌មានទី 1៖ មណ្ឌលសិក្សាធិការបានទិញកង្ហារប្រហែល 3,000 ដែលត្រូវបានផលិតដើម្បីផលិតខ្យល់បរិសុទ្ធយ៉ាងហោចណាស់ 270 ហ្វីតគូបក្នុងមួយនាទី។** វាមានភាពគ្រប់គ្រាន់ក្នុងការទ្រទ្រង់លំហូរខ្យល់បរិសុទ្ធសម្រាប់មនុស្សចំនួន 18 នាក់នៅក្នុងបន្ទប់មុនពេលអនុវត្តលក្ខខណ្ឌតម្រូវនៃការរក្សាគម្លាតសង្គម។ វាក៏មានកង្ហារគ្រប់គ្រាន់សម្រាប់បន្ថែមក្នុងករណីដែលយើងត្រូវការប្តូរវានៅពេលក្រោយក្នុងឆ្នាំសិក្សា។
- **ព័ត៌មានទី 2៖ កង្ហារជាប់បង្អួចត្រូវបានបញ្ជូនទៅអគារសិក្សាទាំងអស់ដែលត្រូវការពួកវា ហើយការដំឡើងបានចាប់ផ្តើមហើយ។** មកទល់នឹងបច្ចុប្បន្ន កង្ហារជាប់បង្អួចច្រើនជាងមួយភាគបីត្រូវបានដំឡើងរួចហើយ។ គោលដៅរបស់យើងគឺត្រូវដំឡើងកង្ហារជាប់បង្អួចទាំងអស់មុនពេលបុគ្គលិកត្រឡប់មកធ្វើការងារវិញនៅថ្ងៃទី 8 ខែកុម្ភៈតាមដែលអាចធ្វើទៅបាន។ លក្ខខណ្ឌអាកាសធាតុថ្មីៗនេះ*អាច*បណ្តាលឲ្យមានការពន្យារពេលបន្តិចលើកាលវិភាគដំឡើងរបស់យើង។
- **ព័ត៌មានទី 3៖ យើងចង់អោយសីតុណ្ហភាពក្នុងថ្នាក់រៀនស្ថិតនៅ ឬខ្ពស់ជាង 68 អង្សាដើម្បីទ្រទ្រង់ដល់បរិយាកាសចូលរៀននៅសាលារៀនដោយមានជាសុខភាពសម្រាប់សិស្ស និងបុគ្គលិក។** យើងបានតេស្តសីតុណ្ហភាពយ៉ាងសកម្មនៅក្នុងគំរូនៃបន្ទប់ដែលមានកង្ហារជាប់បង្អួចដើម្បីវាយតម្លៃឥទ្ធិពល។ នៅគ្រប់ករណីទាំងអស់ សីតុណ្ហភាពនៅក្នុងបន្ទប់នៅតែខ្ពស់ជាង 68

**អង្គភាពប្រតិបត្តិការ**
440 North Broad Street
Philadelphia, PA 19130

អង្ស្រា។ ដូចគ្នានេះផងដែរ នៅពេលចាប់ផ្តើមចូលរៀននៅសាលារៀន វិស្វករអគាររបស់យើងនឹងត្រួតពិនិត្យថ្នាក់រៀនដោយសុវត្ថិភាពដើម្បីធានាថាកង្ហារជាប់បង្អួចមានដំណើរការត្រឹមត្រូវ ហើយសីតុណ្ហភាពក្នុងបន្ទប់គឺសមរម្យ។

ដើម្បីស្វែងយល់បន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងរបស់យើងស្តីពីការបន្សុទ្ធខ្យល់ និងគ្រប់កម្រិតសុវត្ថិភាពទាំងអស់ដែលនឹងត្រូវយកមកអនុវត្តដើម្បីការពារសុខភាពនិងសុខុមាលភាពរបស់មនុស្សគ្រប់គ្នានៅក្នុងសាលារៀនរបស់យើង សូមចូលទៅកាន់ www.philasd.org/aes។

*ក្រុមការងារប្រតិបត្តិការ SDP*